

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

CIAS 23

បន្ទុកលើប្រាក់កម្ចី

Borrowing Costs

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

អារម្ភកថា

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបានន្ូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទ្ូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាព នយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងន្ូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាល កម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើ បច្ចុប្បន្នកម្មជាបន្តបន្ទាប់ន្ូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាល ទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធ ហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និង **ក្រុមប្រឹក្សាជាតិគណនេយ្យ** ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជា ក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិង សវនកម្មឯកជន ដើម្បីបង្កើតន្ូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញ កំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័ន បញ្ជាត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដា គណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច កម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា**" ត្រូវបានបកប្រែ ទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សា ស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅ នឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានា បានន្ូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ពន្ធ៍ទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ពន្ធ៍នៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីសំយកហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ង៉ែ តាយ៉ី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

អារម្ភកថា

ꕥ

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០"**។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី "គណនេយ្យ សហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ" នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន" *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* " និង *"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម"* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍនភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ព័ន្ធ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋលេខាធិការ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

ង៉ី តាយ៉ី

បន្ទុកលើប្រាក់កម្ចីដែលចូលរួមដោយផ្ទាល់នៅក្នុងការទិញ ការសាងសង់ ឬ ផលិតទ្រព្យសកម្ម មិនទាន់ពេញលក្ខណៈ បង្កើតឡើងនូវផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មនោះ។ បន្ទុកលើប្រាក់កម្ចី ផ្សេងទៀតត្រូវបានទទួលស្គាល់ជាចំណាយ

វិសាលភាព

២ អង្គភាពមួយត្រូវអនុវត្តស្តង់ដានេះនៅក្នុងការធ្វើគណនេយ្យកម្មសម្រាប់បន្ទុកលើប្រាក់កម្ចី

៣ ស្តង់ដាមិនជាប់ទាក់ទិនជាមួយនឹងថ្លៃដើមជាក់ស្តែង ឬជាក់បន្ទុកនៃមូលធនទេរួមបញ្ចូលទាំងដើមទុនអនិភាព ដែលមិនត្រូវបានចាត់ថ្នាក់ជាបំណុល។

៤ អង្គភាពមួយមិនត្រូវបានតម្រូវឱ្យប្រើស្តង់ដានេះចំពោះបន្ទុកលើប្រាក់កម្ចីដែលចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង់ ឬ ការផលិតនៃ:

(ក) ទ្រព្យសកម្មមិនទាន់ពេញលក្ខណៈដែលបានវាស់វែង តាមតម្លៃសមស្រប ជាឧទាហរណ៍ ទ្រព្យសកម្មជីវសាស្ត្រ ឬ

(ខ) សន្និធិដែលត្រូវបានផលិត ឬក៏ការផលិតក្នុងបរិមាណច្រើនតាមមូលដ្ឋានដដែលៗ។

និយមន័យ

៥ ស្តង់ដានេះប្រើវាក្យស័ព្ទខាងក្រោមជាមួយនឹងអត្ថន័យបញ្ជាក់ដូចតទៅ:

បន្ទុកលើប្រាក់កម្ចី **គឺជាការប្រាក់ និងថ្លៃដើមផ្សេងទៀតដែលអង្គភាពមួយកើតមានឡើង ដែលជាប់ទាក់ទិននឹងការខ្ចីមូលនិធិ**

ទ្រព្យសកម្មមិនពេញលក្ខណៈ **គឺទ្រព្យសកម្មដែលត្រូវការពេលវេលាច្រើនជាចាំបាច់ដើម្បីធ្វើវារាល់គោលប្រើប្រាស់ ឬ លក់។**

៦ បន្ទុកលើប្រាក់កម្ចីអាចរួមបញ្ចូលទាំង:

(ក) ចំណាយការប្រាក់ដែលបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាពដូចបានចែងនៅក្នុងស.គ.អ.ក ៣៩ *ឧបករណ៍ហិរញ្ញវត្ថុ: ការទទួលស្គាល់ និង ការវាស់វែង*

(ខ) [លុបចោល]

(គ) [លុបចោល]

(ឃ) បន្ទុកហិរញ្ញវត្ថុ ដែលទាក់ទិននឹងភតិសន្យាហិរញ្ញវត្ថុ ដែលបានទទួលស្គាល់ដោយអនុលោមតាម ស.គ.អ.ក ១៧ *ភតិសន្យា* និង

(ង) ភាពខុសគ្នាពីការដោះដូរដែលកើតចេញពីការខ្ចីរូបិយវត្ថុបរទេសចំពោះទំហំដែលការខ្ចីទាំងនោះ ត្រូវបានចាត់ទុកជាការកែសំរួលចំពោះថ្លៃដើមការប្រាក់

៧ ដោយផ្អែកលើកាលៈទេសៈ ទ្រព្យសកម្មខាងក្រោមណាមួយអាចជាទ្រព្យសកម្មមិនទាន់ពេញលក្ខណៈ:

(ក) សន្និធិ

(ខ) រោងចក្រផលិត

(គ) រោងចក្រផលិតថាមពល

(ឃ) ទ្រព្យសកម្មអរូបី

(ង) ទ្រព្យវិនិយោគ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងសន្និធិដែលត្រូវបានផលិត ឬបង្កើតឡើង លើការិយបរិច្ឆេទខ្លី មិនមែនជាទ្រព្យសកម្មមិនពេញលក្ខណៈ។ ទ្រព្យសកម្មដែលរួចរាល់ សម្រាប់គោលបំណងប្រើប្រាស់ ឬការលក់ នៅពេលដែលបានទិញ មិនមែនជាទ្រព្យសកម្មមិនពេញលក្ខណៈទេ។

ការទទួលស្គាល់

៨ អង្គភាពមួយត្រូវធ្វើមូលធនកម្មបន្ទុកលើប្រាក់កម្ចីដែលចូលរួមដោយផ្ទាល់នៅក្នុងការទិញ ការសាងសង់ ឬការផលិតនៃទ្រព្យសកម្មមិនពេញលក្ខណៈដែលជាផ្នែកមួយនៃថ្លៃដើម នៃទ្រព្យសកម្មនោះ។ ទ្រព្យសកម្មត្រូវទទួលស្គាល់បន្ទុកលើប្រាក់កម្ចីជាចំណាយនៅក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

៩ បន្ទុកលើប្រាក់កម្ចីដែលចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង ឬការផលិតទ្រព្យសកម្មមិនទាន់ពេញលក្ខណៈ ត្រូវបានបញ្ចូល នៅក្នុងថ្លៃដើមនៃទ្រព្យសកម្មនោះ។ បន្ទុកលើប្រាក់កម្ចីបែបនេះត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្មនៅពេលដែលវាទំនងថាថ្លៃដើមនោះនឹងនាំឱ្យមានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ចំពោះអង្គភាព និង ថ្លៃដើមអាចត្រូវបានវាស់វែងដោយជឿជាក់។ នៅពេល ដែលអង្គភាពប្រើ ស.គ.អ.ក ២៩ *ការរាយការណ៍ហិរញ្ញវត្ថុ នៅក្នុងសេដ្ឋកិច្ចមានអតិផរណាខ្ពស់ហួសហេតុ* អង្គភាពទទួលស្គាល់ជាចំណាយនូវផ្នែកនៃបន្ទុកលើប្រាក់កម្ចីនោះ ដែលតបស្នងចំពោះអតិផរណាក្នុងកំឡុងការិយបរិច្ឆេទ

ដូចគ្នាដោយអនុលោមតាមកថាខណ្ឌ ២១ នៃស្តង់ដានោះ។

បន្ទុកលើប្រាក់កម្ចីដែលទទួលសិទ្ធិធ្វើមូលធនកម្ម

១០ បន្ទុកលើប្រាក់កំចីដែលចូលរួមដោយផ្ទាល់ចំពោះការទិញ ការសាងសង់ ឬ ការផលិតនៃ ទ្រព្យសកម្មមិនពេញលក្ខណៈ គឺជាបន្ទុកលើប្រាក់កម្ចីទាំង ឡាយណា ដែលអាចត្រូវបានជៀសវាងបាន ប្រសិនបើ ចំណាយលើ ទ្រព្យសកម្មមិនពេញលក្ខណៈមិនត្រូវបានគេបង្កើតវាឡើងទេនោះ ។ នៅពេលដែលអង្គភាពមួយខ្ចីមូលធិនិមានគោលបំណងជាក់នៃការទទួល បានទ្រព្យសកម្មមិនពេញលក្ខណៈជាក់លាក់ បន្ទុកលើប្រាក់កំចីដែល ទាក់ទិនផ្ទាល់នៃទ្រព្យសកម្មមិនពេញលក្ខណៈនោះអាចត្រូវបានគេកំណត់ រួចរាល់ ។

១១ វាមានការលំបាក ដើម្បីធ្វើអត្តសញ្ញាណពីទំនាក់ទំនងដោយផ្ទាល់រវាងកម្ចី ជាក់លាក់ និងទ្រព្យសកម្មមិនពេញលក្ខណៈ និងមានការលំបាក ដើម្បី កំណត់ពីកម្ចីដែលអាចត្រូវបានគេជៀសវាង។ ការលំបាកទាំងនេះ កើត មានឡើង ជាឧទាហរណ៍ នៅពេលដែលសកម្មភាពហិរញ្ញប្បទានរបស់ អង្គភាពមួយគឺត្រូវបានសម្របសម្រួលនៅថ្នាក់កណ្តាល ។ ភាពលំបាក ទាំងនេះក៏កើតមានឡើងផងដែរនៅពេល ដែលបណ្តុំក្រុមហ៊ុនប្រើប្រាស់ ឧបករណ៍បំណុលច្រើនប្រភេទដើម្បីខ្ចីមូលនិធិតាមអត្រាការប្រាក់ខុសៗគ្នា និងឱ្យខ្ចី មូលនិធិទាំងនោះផ្អែកលើមូលដ្ឋានផ្សេងៗ ចំពោះអង្គភាព ផ្សេងទៀតនៅ ក្នុងបណ្តុំក្រុមហ៊ុន។ ភាពស្មុគស្មាញផ្សេងទៀត កើតឡើង តាមរយៈការប្រើ កម្ចីដែលបានកំណត់ជា ឬជាប់ទាក់ទង នឹងរូបិយវត្ថុ

បរទេស នៅពេលដែល បណ្តុំ ក្រុមហ៊ុនធ្វើកិច្ចប្រតិបត្តិ នៅក្នុងសេដ្ឋកិច្ច ដែលមានអតិផរណាខ្ពស់ និងពីការឡើងចុះអត្រាប្តូរប្រាក់។ ជាលទ្ធផល ការកំណត់ពីទឹកប្រាក់បន្ទុក លើប្រាក់កម្ចី ដែលចូលរួមដោយផ្ទាល់ទៅនឹង ការទិញទ្រព្យសកម្ម មិនពេញ លក្ខណៈមានការលំបាក ហើយការ ប្រើប្រាស់ការធ្វើការវិនិច្ឆ័យត្រូវបាន តម្រូវឱ្យមាន។

១២ តាមទំហំដែលអង្គភាពមួយខ្ចីមូលនិធិ សម្រាប់គោលបំណងជាក់លាក់នៃការទទួលបានទ្រព្យសកម្មមិនពេញលេញ អង្គភាពត្រូវបានកំណត់ពីទឹកប្រាក់នៃបន្ទុកលើប្រាក់កម្ចីដែលទទួលសិទ្ធិឱ្យធ្វើមូលធនកម្ម ជាបន្ទុកលើប្រាក់កម្ចីជាក់លាក់ដែលបានកើតឡើងលើកម្ចីនោះក្នុងកំឡុងការិយបរិច្ឆេទ ដកចេញនូវចំណូល ពីការវិនិយោគណាមួយលើការវិនិយោគបណ្តោះអាសន្ននៃកម្ចីទាំងនោះ ។

១៣ ការរៀបចំហិរញ្ញប្បទាន សម្រាប់ទ្រព្យសកម្មមិនពេញលក្ខណៈ អាចកើតមាន នៅក្នុងអង្គភាពមួយក្នុងការទទួលបានមូលនិធិបានខ្ចីនិងកើតឡើងនូវបន្ទុក លើប្រាក់កម្ចីដែលពាក់ព័ន្ធមុនពេលមូលនិធិទាំងអស់ឬមូលនិធិខ្លះត្រូវបាន ប្រើសម្រាប់ការចំណាយលើទ្រព្យសកម្មមិនពេញលក្ខណៈ។ នៅក្នុងកាលៈ ទេសៈបែបនេះ មូលនិធិជាទូទៅត្រូវបានវិនិយោគ បណ្តោះអាសន្នដែលរង ចាំការចំណាយលើទ្រព្យសកម្មមិនពេញលក្ខណៈ។ នៅក្នុងការកំណត់ទឹក ប្រាក់នៃបន្ទុកលើប្រាក់កម្ចីដែលទទួល សិទ្ធិសម្រាប់ការធ្វើមូលធនកម្មក្នុង កំឡុងការិយបរិច្ឆេទមួយ ចំណូលពីការ វិនិយោគណាមួយ ដែលរកបានពី មូលនិធិបែបនេះ ត្រូវបានកាត់ចេញពីបន្ទុកលើប្រាក់កម្ចីដែលបានកើតឡើង ។

១៤ តាមទំហំដែលអង្គភាពមួយខ្ចីមូលនិធិជាទូទៅ និងប្រើប្រាស់មូលនិធិសម្រាប់ គោលបំណងនៃការទទួលបានទ្រព្យសកម្មមិនពេញលក្ខណៈអង្គភាពត្រូវ កំណត់ពីទឹកប្រាក់នៃបន្ទុកលើប្រាក់កម្ចីដែលទទួលសិទ្ធិសម្រាប់ការធ្វើ មូលធនកម្មដោយការប្រើអត្រាមូលធនកម្មធៀបនឹងចំណាយលើទ្រព្យ សកម្មនោះ។ អត្រាមូលធនកម្មត្រូវបានគិតជាមធ្យមនៃបន្ទុកលើប្រាក់កម្ចី ដែលអាចអនុវត្តបានចំពោះកម្ចីរបស់អង្គភាពដែលនៅមានក្នុងកំឡុង ការិយបរិច្ឆេទ ជាជាងកម្ចីដែលបានធ្វើឡើងសំរាបីគោលបំណងជាក់លាក់ នៃការទទួលបានទ្រព្យសកម្មមិនពេញលក្ខណៈ។ ទឹកប្រាក់នៃបន្ទុកលើ ប្រាក់កម្ចីដែលអង្គភាពមួយធ្វើមូលធនកម្មក្នុងកំឡុងការិយបរិច្ឆេទមួយមិន ត្រូវលើសពីទឹកប្រាក់នៃបន្ទុកលើប្រាក់កម្ចីដែលកើតឡើងក្នុងកំឡុងការិយបរិច្ឆេទនោះ។

១៥ នៅក្នុងកាលៈទេសៈមួយចំនួន វាមានភាពសមស្របដើម្បីបញ្ចូលកម្ចីទាំងអស់របស់ ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅពេលដែលធ្វើការគណនាអត្រាមធ្យមនៃបន្ទុកលើប្រាក់កម្ចី នៅក្នុងកាលៈទេសៈ ផ្សេងទៀតវាមានភាពសមស្របសម្រាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗ ដើម្បីប្រើអត្រាមធ្យមនៃបន្ទុកលើប្រាក់ កម្ចីដែលអាចអនុវត្តបានចំពោះកំចីផ្ទាល់របស់ខ្លួន។

ទឹកប្រាក់លើសនៃតម្លៃយោងនៃទ្រព្យសកម្មមិនពេញលក្ខណៈលើតម្លៃអាចទទួលបានមកវិញ

១៦ នៅពេលដែលតម្លៃយោង ឬថ្លៃដើមចុងក្រោយបង្អស់ ដែលបានរំពឹងទុកនៃទ្រព្យសកម្មមិនពេញលក្ខណៈ លើសពីទឹកប្រាក់ដែលអាចទទួលបាន

មកវិញ ឬតម្លៃទទួលពិត តម្លៃយោងត្រូវបានបន្ថយ ឬត្រូវបានលុបចោល ដោយអនុលោមតាមការតំរូវនៃស្តង់ដាផ្សេងទៀត។ នៅក្នុងកាលៈទេសៈជាក់លាក់ ទឹកប្រាក់នៃការធ្លាក់ចុះតម្លៃ ឬលុបចោលនោះត្រូវបានកត់ត្រាត្រឡប់វិញដោយអនុលោមតាមស្តង់ដាផ្សេងទៀត។

ការចាប់ផ្តើមធ្វើមូលធនកម្ម

១៧ អង្គភាពមួយត្រូវចាប់ផ្តើមធ្វើមូលធនកម្មបន្ទុកលើប្រាក់កម្ចីជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មមិនពេញលក្ខណៈនៅកាលបរិច្ឆេទចាប់ផ្តើមធ្វើមូលធនកម្ម។ កាលបរិច្ឆេទចាប់ផ្តើមធ្វើមូលធនកម្មគឺកាលបរិច្ឆេទ ដែលអង្គភាពបំពេញ ជាបឋម នូវលក្ខខណ្ឌទាំងអស់ខាងក្រោម៖

(ក) អង្គភាពកើតមានចំណាយសម្រាប់ទ្រព្យសកម្ម

(ខ) អង្គភាពកើតឡើងបន្ទុកលើប្រាក់កម្ចី និង

(គ) អង្គភាពអនុវត្តសកម្មទាំងឡាយដែលចាំបាច់ ដើម្បីរៀបចំទ្រព្យសកម្ម សម្រាប់គោលបំណងប្រើប្រាស់ ឬការលក់។

១៨ ការចំណាយលើទ្រព្យសកម្មមិនពេញលក្ខណៈ រួមបញ្ចូលតែចំណាយណាដែលនាំដល់ការទូទាត់ជាសាច់ប្រាក់ ការផ្ទេរទ្រព្យសកម្មផ្សេងទៀត ឬ ការសន្មត់នៃបំណុលមានការប្រាក់។ ចំណាយត្រូវបានកាត់បន្ថយ ដោយការទូទាត់ជាដំណាក់កាលដែលបានទទួល និងអំណាយ ដែលបានទទួលទាក់ទិននឹងទ្រព្យសកម្ម (សូមមើល ស.គ.អ.ក ២០ *ការធ្វើគណនេយ្យកម្ម*

សម្រាប់អំណោយរបស់ រដ្ឋាភិបាល និងការលាតត្រដាង នៃជំនួយរបស់ រដ្ឋាភិបាល)។ តម្លៃយោងមធ្យមនៃទ្រព្យសកម្មក្នុងកំឡុងការិយបរិច្ឆេទមួយ រួមបញ្ចូលទាំងបន្ទុកលើប្រាក់កម្ចី ដែលបានធ្វើមូលធនកម្មពីមុនជាធម្មតាជាការប៉ាន់ស្មានសមស្របមួយនៃចំណាយដែល អត្រាមូលធនកម្មត្រូវបានប្រើនៅក្នុងការិយបរិច្ឆេទនោះ ។

១៩ សកម្មភាពទាំងឡាយ ដែលចាំបាច់ដើម្បីរៀបចំទ្រព្យសកម្ម សម្រាប់គោលបំណងប្រើប្រាស់ ឬលក់ មានច្រើនជាងការសាងសង់ទ្រព្យសកម្មរូបវន្ត។ សកម្មភាពទាំងនោះរួមមានការរដ្ឋបាល និងបច្ចេកទេស មុនការចាប់ផ្តើមនៃការសាងសង់រូបវន្ត ដូចជា សកម្មភាពដែលជាប់ពាក់ព័ន្ធនឹងការទទួលបានការអនុញ្ញាតមុនការចាប់ផ្តើមនៃការសាងសង់រូបវន្ត។ ប៉ុន្តែ សកម្មភាពទាំងនេះមិនបញ្ចូលការកាន់កាប់ ទ្រព្យសកម្ម ពេលដែលឈប់កើតមានការផលិត ឬការអភិវឌ្ឍដែលធ្វើឱ្យប្រែប្រួលលក្ខខណ្ឌរបស់ទ្រព្យសកម្ម។ ឧទាហរណ៍ បន្ទុកលើប្រាក់កម្ចីដែលបានកើតឡើងខណៈ ដែលដីស្ថិតនៅក្រោមការអភិវឌ្ឍ ត្រូវបានធ្វើមូលធនកម្មក្នុងកំឡុងការិយបរិច្ឆេទ ដែលសកម្មទាំងឡាយដែលទាក់ទិននឹងការអភិវឌ្ឍត្រូវបានកំពុងអនុវត្ត។ ប៉ុន្តែ បន្ទុកលើប្រាក់កម្ចីដែលកើតមានខណៈដែលដីដែលបានទិញ សម្រាប់គោលបំណងសាងសង់ ត្រូវបានកាន់កាប់ដោយគ្មាន សកម្មភាពអភិវឌ្ឍទាន់ទិនណាទេ មិនបំពេញលក្ខណៈឱ្យការធ្វើមូលធនកម្មទេ។

ការផ្អាកមូលធនកម្ម

២០ អង្គភាពមួយ ត្រូវផ្អាកធ្វើមូលធនកម្មនៃបន្ទុកលើប្រាក់កម្ចីក្នុងកំឡុងការិយបរិច្ឆេទបន្ថែម ដែលអង្គភាពផ្អាកការអភិឌ្ឍជ័សកម្មនៃ ទ្រព្យសកម្ម

មិនពេញលក្ខណៈ។

២១ អង្គភាពមួយ អាចកើតមានបន្ទុកលើប្រាក់កម្ចី ក្នុងកំឡុងការិយបរិច្ឆេទបន្ថែមដែលអង្គភាព ផ្អាកសកម្មភាពទាំងឡាយ ដែលចាំបាច់ដើម្បីរៀចចំទ្រព្យសកម្មមួយសម្រាប់គោលបំណងប្រើប្រាស់ ឬលក់។ ថ្លៃដើមបែបនោះគឺជាថ្លៃដើមនៃការកាន់កាប់ទ្រព្យសកម្មបានបញ្ចប់បានមួយផ្នែក និងមិនបំពេញលក្ខណៈឱ្យមូលធនកម្ម។ ប៉ុន្តែ អង្គភាពមួយជាធម្មតាមិនផ្អាកការធ្វើមូលធនកម្មបន្ទុកលើប្រាក់កម្ចីទេក្នុងការិយបរិច្ឆេទមួយនៅពេល ដែលអង្គភាពអនុវត្តការងារដ្ឋបាល និងការងារបច្ចេកទេសសំខាន់ៗ។ អង្គភាពមួយក៏មិនផ្អាកផងដែរក្នុងធ្វើ មូលធនកម្មបន្ទុកលើប្រាក់កម្ចី នៅពេលដែលការពន្យាបណ្តោះអាសន្ន ជាផ្នែកចាំបាច់មួយនៃដំណើរការ ដើម្បីទទួលបានទ្រព្យសកម្មមួយដែលមានលក្ខណៈរួចរាល់សម្រាប់គោលបំណងប្រើប្រាស់ ឬលក់។ ឧទាហរណ៍ ការធ្វើមូលធនកម្មបន្ត ធ្វើក្នុងកំឡុងការិយបរិច្ឆេទបន្ថែមដែលកំរិតទឹកខ្ពស់ពន្យាការសាងសង់ស្ពាន ប្រសិនបើកំរិត ទឹកខ្ពស់បែបនេះតែងតែកើតមានក្នុងកំឡុងការិយបរិច្ឆេទសាងសង់នៅក្នុងតំបន់ភូមិសាស្ត្រពាក់ព័ន្ធ។

ការឈប់ធ្វើមូលធនកម្ម

២២ អង្គភាពមួយត្រូវឈប់ធ្វើមូលធនកម្មលើបន្ទុកលើប្រាក់កម្ចីនៅពេលដែលសកម្មភាពចាំបាច់ទាំងអស់
ដើម្បីរៀបចំទ្រព្យសកម្មមិនពេញលក្ខណៈសម្រាប់ គោលបំណងប្រើប្រាស់ ឬ លក់ត្រូវបានបញ្ចប់។

២៣ ទ្រព្យសកម្មមួយជាធម្មតារួចរាល់សម្រាប់ប្រើប្រាស់ ឬលក់នៅពេលដែល

ការសាងសង់រូបវន្តនៃទ្រព្យសកម្ម ត្រូវបានបញ្ចប់ទោះបីជាការងាររដ្ឋបាលអាចនៅបន្តក៏ដោយ។ ប្រសិនបើមានការកែប្រែបន្តិចបន្តួច ដូចជា ការតុបតែងទ្រព្យចំពោះចំណុចជាក់លាក់របស់ឱ្យអ្នកទិញ ឬអ្នកប្រើប្រាស់ គឺទាំងអស់នេះនៅសេសសល់ នេះបង្ហាញថាសកម្មភាពសំខាន់ៗទាំងអស់ ត្រូវបានចប់សព្វគ្រប់ហើយ។

២៤ នៅពេលដែលអង្គភាពបញ្ចប់ការងារសាងសង់ទ្រព្យសកម្មមិនពេញលក្ខណៈដោយផ្នែក ហើយផ្នែកនីមួយៗអាចត្រូវបានកំពុងប្រើខណៈដែលការសាងសង់បន្តនៅលើផ្នែកផ្សេងទៀត អង្គភាពឈប់ធ្វើមូលធនកម្មបន្ទុកលើប្រាក់កម្ចីនៅពេលដែលអង្គភាពបញ្ចប់សកម្មភាពសំខាន់ៗទាំងអស់ដែលចាំបាច់ដើម្បីរៀបចំផ្នែក នោះសម្រាប់គោលបំណងប្រើប្រាស់ ឬ លក់។

២៥ សួនពាណិជ្ជកម្មដែលរួមបញ្ចូលទាំងអគារមួយចំនួនផងនោះ អគារនីមួយៗអាចត្រូវបានប្រើមួយៗ គឺជាឧទាហរណ៍នៃទ្រព្យសកម្មមិនពេញលក្ខណៈសម្រាប់ផ្នែកនីមួយៗ ដែលអាចប្រើបានខណៈ ដែលការសាងសង់បន្តលើផ្នែកផ្សេងទៀត។ ឧទាហរណ៍នៃទ្រព្យសកម្មមិនពេញលក្ខណៈដែលចាំបាច់ត្រូវតែបញ្ចប់មុនពេលផ្នែកណាមួយ អាចត្រូវបានប្រើគឺជារោងចក្រឧស្សាហកម្មដែលទាក់ទិននឹងដំណើរការមួយចំនួនដែលត្រូវបានអនុវត្តតាមលេខរៀងនៅផ្នែកខុសៗគ្នានៃរោងចក្រនៅក្នុងទីតាំងដូចគ្នា ដូចជារោងចក្រដែកថែប។

២៦ អង្គភាពមួយត្រូវលាតត្រដាង៖

(ក) ទឹកប្រាក់នៃបន្ទុកលើប្រាក់កម្ចីដែលបានធ្វើមូលធនកម្មក្នុងកំឡុងការិយបរិច្ឆេទ និង

(ខ) អត្រាមូលធនកម្មដែលបានប្រើដើម្បីកំណត់ទឹកប្រាក់នៃបន្ទុកលើប្រាក់កម្ចីដែលទទួលសិទ្ធិធ្វើមូលធនកម្ម។

អនុវត្តបញ្ញត្តិ

២៧ នៅពេលដែលការអនុវត្តនៃស្តង់ដានេះបង្កបង្កើតឱ្យមានការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ អង្គភាព ត្រូវប្រើស្តង់ដាចំពោះបន្ទុកលើប្រាក់កម្ចី ដែលទាក់ទិននឹងទ្រព្យសកម្មមិនពេញលក្ខណៈ សម្រាប់កាលបរិច្ឆេទចាប់ផ្តើម សម្រាប់មូលធនកម្មគឺនៅកាលបរិច្ឆេទ ឬបន្ទាប់ពីកាលបរិច្ឆេទប្រសិទ្ធិភាព។

២៨ ប៉ុន្តែ អង្គភាពមួយអាចកំណត់កាលបរិច្ឆេទណាមួយមុនពេលកាលបរិច្ឆេទប្រសិទ្ធិភាព ហើយប្រើស្តង់ដាចំពោះបន្ទុកលើ ប្រាក់កម្ចី ដែលទាក់ទិននឹងទ្រព្យសកម្មមិនពេញលក្ខណៈទាំងអស់សម្រាប់កាលបរិច្ឆេទចាប់ផ្តើមធ្វើមូលធនកម្មនៅកាលបរិច្ឆេទ ឬ បន្ទាប់ពី កាលបរិច្ឆេទនោះ ។

កាលបរិច្ឆេទប្រសិទ្ធិភាព

២៩ អង្គភាពត្រូវអនុវត្តស្តង់ដា សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាំផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុនត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយអនុវត្តស្តង់ដានេះចាប់ពីកាលបរិច្ឆេទមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ។

២៩ក កថាខណ្ឌ ៦ ត្រូវបានធ្វើវិសោធនកម្មដោយ *ការធ្វើឱ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយនៅក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពមួយត្រូវប្រើវិសោធនកម្មនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើម នៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុនត្រូវបានអនុញ្ញាត ។ ប្រសិនបើអង្គភាពមួយប្រើវិសោធនកម្មសម្រាប់ការិយបរិច្ឆេទមុន អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ

ការដកចេញនៃ ស.គ.អ.ក ២៣ (បានកែប្រែ ឆ្នាំ ១៩៩៣)

៣០ ស្តង់ដានេះជំនួសឱ្យ ស.គ.អ.ក ២៣ *បន្ទុកលើប្រាក់កម្ចី* ដែលបានកែប្រែនៅក្នុងឆ្នាំ ១៩៩៣។

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា

អាស័យដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ